**បទឧទ្ទេសនាម**

**របស់**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ក្នុងកិច្ចប្រជុំពេញអង្គរដ្ឋសភា**

**ស្តីពី**

# សេចក្តីព្រាងច្បាប់ស្តីពី
# ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០

***វិមានរដ្ឋសភា, ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២១***

**ជាថ្មីម្តងទៀត, ខ្ញុំបាទសូមគោរព៖**

- **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់**;
- **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប អនុប្រធានទី ១ នៃរដ្ឋសភា**;
- **លោកជំទាវកិត្តិសង្គហបណ្ឌិត ឃួន សុដារី អនុប្រធានទី ២ នៃរដ្ឋសភា**;
- **សម្តេច**, **ឯកឧត្តម**, **លោកជំទាវ**, **សមាជិក**, **សមាជិកានៃរដ្ឋសភា និង អង្គរដ្ឋសភា ដ៏ឧត្តុង្គឧត្តម**!

ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា,** ខ្ញុំបាទសូមគោរពធ្វើបទឧទ្ទេសនាមដោយសង្ខេប លើចំណុចសំខាន់ៗមួយចំនួន ពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០ និង គោរពសុំការអធ្យាស្រ័យជាមុន ក្នុងករណីដែលខ្ញុំបាទអាចថ្លែងឡើងវិញ ក្នុងគោលដៅគូសបញ្ជាក់ ឬ សង្កត់ធ្ងន់បន្ថែម ឬ សម្រួចបន្ថែម នូវចំណុចមួយចំនួននៅក្នុងបទឧទ្ទេសនាមនេះ ដែលអាចជាន់គ្នានឹងអ្វីដែល **ឯកឧត្តម ឈាង វុន** ក្នុងនាមគណៈកម្មការទី ២ បានរាយការណ៍ជូនអង្គរដ្ឋសភាមុននេះ ។

## ១. លទ្ធផលផ្នែកម៉ាក្រូសេដ្ឋកិច្ច

សេដ្ឋកិច្ចកម្ពុជា នាឆ្នាំ ២០២០ ត្រូវបានវាយតម្លៃថា មានកំណើនអវិជ្ជមាន -៣,១% ដោយសារឥទ្ធិពលនៃវិបត្តិជំងឺកូវីដ-១៩ ដែលបានបណ្តាលឱ្យវិស័យជំរុញកំណើនសំខាន់ៗ ទទួលរងផលប៉ះពាល់គួរឱ្យកត់សម្គាល់ ក្នុងនោះរួមមាន៖ អនុវិស័យសណ្ឋាគារ និង ភោជនីយដ្ឋាន, អនុវិស័យកាត់ដេរ, អនុវិស័យលក់ដុំ និង លក់រាយ, អនុវិស័យសំណង់ និង អចលនទ្រព្យ និង អនុវិស័យដឹកជញ្ជូន ។ លើមូលដ្ឋាននេះ, ផសស សម្រាប់មនុស្សម្នាក់ បាន ធ្លាក់ចុះមកនៅត្រឹម ១ ៦៥៣ ដុល្លារអាមេរិក ក្នុងឆ្នាំ ២០២០ ពី ១ ៧០០ ដុល្លារអាមេរិក ក្នុង ឆ្នាំ ២០១៩ ។ ទន្ទឹមនឹងនេះ, អតិផរណាមធ្យម បានកើនឡើងមកក្នុងអត្រា ២,៩% ក្នុង ឆ្នាំ ២០២០ ពីអត្រា ១,៨% ក្នុងឆ្នាំ ២០១៩ ស្របពេលដែលអត្រាប្តូរប្រាក់ស្ថិត ក្នុងកម្រិត ៤ ០៨០ រៀល ក្នុងមួយដុល្លារអាមេរិក ។

## ២. លទ្ធផលនៃការអនុវត្តថវិកា

### ក-ផ្នែកចំណូលថវិកា

ចំណូលថវិការដ្ឋ ឆ្នាំ ២០២០, ដែលរួមបញ្ចូលនូវ ថវិកាថ្នាក់ជាតិ និង ថវិកាថ្នាក់ ក្រោមជាតិ, អនុវត្តបានចំនួន ៣១ ៧៧០ ០៨២,៩ លានរៀល, ស្មើនឹង ២៩,១៣% នៃ ផសស គឺទាបជាងច្បាប់ហិរញ្ញវត្ថុ ៦,៣% ដោយក្នុងនោះ៖ (១)-*ចំណូលក្នុងប្រទេស* អនុវត្តបានចំនួន ២៣ ៩២១ ៩៤៨,៣ លានរៀល, ស្មើនឹង ២១,៩៣% នៃ ផសស, គឺ ទាបជាងច្បាប់ហិរញ្ញវត្ថុ ៩,៧% ដោយសារការថមថយនៃសកម្មភាពអាជីវកម្មនានា ដែល រងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ និង ការអនុវត្តវិធានការអនុគ្រោះ ឬ បន្ធូរបន្ថយពន្ធ របស់រាជរដ្ឋាភិបាល; និង (២)- *ចំណូលមូលធនក្រៅប្រទេស* អនុវត្តបានចំនួន ៦ ៨៩៤ ១៣៩,៦ លានរៀល ស្មើនឹង ៦,៣២% នៃ ផសស, គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ ៩,៤% ។

### ខ-ផ្នែកចំណាយថវិកា

នៅក្នុងឆ្នាំ ២០២០, ចំណាយថវិការដ្ឋ, ទាំងថវិកាថ្នាក់ជាតិ និង ថវិកាថ្នាក់ក្រោមជាតិ, អនុវត្តបានចំនួន ៣២ ៧៣២ ៥២៦,៤ លានរៀល, ស្មើនឹង ៣០,០១% នៃ ផសស, គឺ ទាបជាងច្បាប់ហិរញ្ញវត្ថុ ៤,៤% ដោយក្នុងនោះ ៖

**ខ.១-ចំណាយថវិកាថ្នាក់ជាតិ** អនុវត្តបានចំនួន ២៩ ៥០២ ៧៤៦,៥ លានរៀល រួមមាន ៖ (១)-ចំណាយចរន្ត អនុវត្តបានចំនួន ១៧ ៣៤៥ ៣៤៤,១ លានរៀល; និង (២)-ចំណាយមូលធន អនុវត្តបានចំនួន ១២ ១៥៧ ៤០២,៤ លានរៀល ។

**ខ.២-ចំណាយថវិកាថ្នាក់ក្រោមជាតិ** អនុវត្តបានលទ្ធផល ដូចតទៅ ៖ (១)-ចំណាយ ថវិការបស់រដ្ឋបាលរាជធានី-ខេត្ត អនុវត្តបានចំនួន ១ ៩៤២ ៤៨៧,៥ លានរៀល;

(២)-ចំណាយថវិការបស់រដ្ឋបាលក្រុង-ស្រុក អនុវត្តបានចំនួន ២៦៣ ៥០៤,៩ លានរៀល; និង (៣)-ចំណាយថវិការបស់រដ្ឋបាលឃុំ-សង្កាត់ អនុវត្តបានចំនួន ៦៥១ ៧៣០,៦ លានរៀល ។

ជាការឆ្លើយតបនឹងវិបត្តិជំងឺកូវីដ-១៩, ក្នុងឆ្នាំ ២០២០ រាជរដ្ឋាភិបាលបានធ្វើវិចារណកម្មថវិកា ដោយបានកាត់បន្ថយ ឬ ផ្អាក ឬ លុប នូវមុខសញ្ញាចំណាយណាដែលមិនចាំបាច់, មិនសូវចាំបាច់ និង លែងចាំបាច់ ហើយបង្វែរធនធានទៅដោះស្រាយការងារអាទិភាពចំនួន ៤ រួមមាន ៖ (១)-ការប្រយុទ្ធនឹងជំងឺកូវីដ-១៩, (២)-ការរក្សាលំនឹងជីវភាពប្រជាជន ជាពិសេសសម្រាប់ប្រជាជនក្រីក្រ និង អ្នកបាត់បង់ការងារ, (៣)-ការខិតខំជួយឱ្យអស់លទ្ធភាព ដើម្បីឱ្យធុរកិច្ច និង អាជីវកម្មអាចរស់បាន, និង (៤)-ការរក្សាឱ្យបាននូវសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និង ស្ថិរភាពសង្គម ។

ជារួម, ការអនុវត្តចំណាយថវិកា ឆ្នាំ ២០២០ បានគាំទ្រដល់គោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការដោះស្រាយវិបត្តិជំងឺកូវីដ-១៩ និង ការបន្តអនុវត្តគោលនយោបាយគាំពារសង្គម, ក៏ដូចជាការបន្តអនុវត្តកម្មវិធីកែទម្រង់នានា, ការពង្រីកវិសាលភាពនៃការផ្តល់សេវាសាធារណៈ និង ការវិនិយោគលើធនធានមនុស្ស ព្រមជាមួយនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សំដៅជំរុញពិពិធកម្មសេដ្ឋកិច្ច និង លើកកម្ពស់ភាពប្រកួតប្រជែង ។

## គ-តុល្យភាពចំណូល-ចំណាយថវិកា

**គ១-តុល្យភាពចំណូល-ចំណាយថវិកាថ្នាក់ជាតិ** មានឱនភាពពីការអនុវត្តថវិកាក្នុងឆ្នាំ ចំនួន -១ ០០២ ៣៧៤,០ លានរៀល ដែលត្រូវបានបំពេញដោយប្រាក់សន្សំរបស់រាជរដ្ឋាភិបាល ។

**គ២-តុល្យភាពចំណូល-ចំណាយថវិកាថ្នាក់ក្រោមជាតិ** សម្រេចបានលទ្ធផលដូចខាងក្រោម ៖

- ថវិការបស់រដ្ឋបាលរាជធានី-ខេត្ត មានអតិរេកចំនួន +២៦៨ ៦៥៩,១ លានរៀល ដែលត្រូវបានផ្ទេរចូលគណនីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិនៅរតនាគារជាតិ ដើម្បីយោងបន្តទៅឆ្នាំខាងមុខ;
- ថវិការបស់រដ្ឋបាលក្រុង-ស្រុក មានអតិរេកចំនួន +៩ ៤៥៨,៥ លានរៀល ដែលត្រូវបានផ្ទេរចូលគណនីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិនៅរតនាគារជាតិ ដើម្បីយោងបន្តទៅឆ្នាំខាងមុខ;
- ថវិការបស់រដ្ឋបាលឃុំ-សង្កាត់ មានអតិរេកចំនួន +១៩៤ ៤៩៩,៧ លានរៀល ដែលត្រូវបានកត់ត្រាចូលគណនីលទ្ធផលនៃរតនាគារជាតិ ដើម្បីយោងបន្តទៅឆ្នាំខាងមុខ ។

## ៣. សេចក្ដីសន្និដ្ឋាន

ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចសកល និង ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច មានការវិវត្ត ឆាប់រហ័ស និង ចល័តយ៉ាងលឿនពិបាកប៉ាន់ប្រមាណឱ្យបានច្បាស់លាស់ ដោយសារ ផលប៉ះពាល់ធ្ងន់ធ្ងរនៃការរីករាលដាលនៃជំងឺកូវីដ-១៩, រាជរដ្ឋាភិបាលបានធ្វើការវាយតម្លៃ ឡើងវិញលើក្របខ័ណ្ឌថវិកាឆ្នាំ ២០២០ និង បានសម្រេចបង្វែរទិសនៃការគ្រប់គ្រងហិរញ្ញ-វត្ថុសាធារណៈពី **"ថវិកាវិត្ថារកម្ម"** ដើម្បីលើកកម្ពស់កំណើន ទៅជា **"ថវិកាវីតបន្តឹងសំដៅ បង្កើនប្រសិទ្ធភាពចំណាយ"**, តាមរយៈការធ្វើវិចារណកម្មចំណាយចំនួន ២ លើក, ដើម្បី បម្រើឱ្យការប្រយុទ្ធនឹងជំងឺកូវីដ-១៩, ការរក្សាលំនឹងសេដ្ឋកិច្ច និង ការទ្រទ្រង់ការងារកែ-ទម្រង់របស់រាជរដ្ឋាភិបាល, ក៏ដូចជាបម្រើឱ្យការត្រៀមខ្លួន និង ការពង្រឹងសមត្ថភាពផ្ទៃក្នុង ឱ្យបានល្អ សម្រាប់ត្រៀមទប់ទល់នឹងបញ្ហាប្រឈម និង ហានិភ័យ, ទាំងក្នុង និង ក្រៅ-ប្រទេស, ពិសេសដើម្បីគោលដៅនៃការអនុវត្តឱ្យចេញជាលទ្ធផលជាក់ស្តែង ប្រកបដោយ ប្រសិទ្ធភាព នូវ **កម្មវិធីនយោបាយ, យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជាតិ ឆ្នាំ ២០១៩-២០២៣** របស់រាជ-រដ្ឋាភិបាល ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចអគ្គមហាពញាចក្រី** និង អង្គរដ្ឋសភាទាំងមូល មេត្តាពិនិត្យ និង អនុម័តនូវសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០ ដោយក្តីអនុគ្រោះ ។

***សូមអរគុណ!***